ដាក់ផលវិបាកក្រោយពេលកើត

ការបំបៅនៅពេលចាកចេញពីមន្ទីរពេទ្យ បៅដោះ /បៅចេញពីដប

ការលំបាកក្នុងការបំបៅ

កាលបរិច្ឆេទនៃការចាកចេញពីមន្ទីរពេទ្យ / / ទម្ងន់នៅពេលចាកចេញពីមន្ទីរពេទ្យ (គក្រ)
បរិមាត្រក្បាល (សម)

ហត្ថលេខា

មុខងារ

ទៅទំព័រមាតិកា

បិតស្លាកអ្នកជំងឺនៅទីនេះ

SMR010005

# ការពិនិត្យសុខភាពទារកដែលទើបកើតមក

ផ្នែកនេះត្រូវបំពេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាព នៅចំពោះវត្តមានឪពុកម្ដាយ មុនពេលទារកចាកចេញពីមន្ទីរពេទ្យ។

ថ្ងៃខែឆ្នាំកំណើត / / អាយុទារក ភេទ ប / ស

ឈ្មោះទារក

| ការពិនិត្យ | ធម្មតា | មតិយោបល់ |
|---|---|---|
| ក្បាល និងបង្ហើយទារក | | |
| ភ្នែក<br>(ការសង្កេតទូទៅ រួមទាំងការភ្លោចទៅនឹងពណ៌ក្រហម) | | |
| ត្រចៀក | | |
| មាត់ និងក្រអូមមាត់ | | |
| សរសៃឈាមបេះដូង | | |
| ជីពចរភ្លៅ ស / ឆ | | |
| អត្រាដកដង្ហើម | | |
| ពោះ និងផ្ចិត | | |
| គូថ | | |
| ប្រដាប់បន្តពូជ | | |
| ពងស្វាសធ្លាក់ចុះទាំងស្រុង ស / ឆ | | |
| សាច់ដុំឆ្អឹង | | |
| ត្រគាក | | |
| ស្បែក | | |
| ភាពភ្លោច | | |
| តើម្ដាយមានកង្វល់ណាមួយអំពីទារករបស់គាត់ដែរឬទេ? | មាន / អត់<br>សូមគូសជារង្វង់ដើម្បីឆ្លើយតប | |

អ្នកពិនិត្យ (សរសេរឈ្មោះជាអក្សរធំ)

មុខងារ

ហត្ថលេខា កាលបរិច្ឆេទ / /

# សំណួរសម្រាប់ឪពុកម្តាយអំពីសោតវិញ្ញាណ

សូមគូសជារង្វង់ ' បាទ/ចាស' ឬ 'ទេ' ចំពោះសំណួរទាំងឡាយខាងក្រោមនេះ
ដើម្បីឱ្យការតាមដានសមស្រប ត្រូវបានអនុវត្តដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាពរបស់អ្នក។

| | |
|---|---|
| ខ្ញុំបានបំពេញសំណួរអំពីកត្តាហានិភ័យផ្នែកសុខភាពនៅទំព័រ 21 រួចហើយ | ទេ \| បាទ/ចាស |
| កូនរបស់ខ្ញុំមានបញ្ហាក្នុងការដេកដង្ហើមធ្ងន់ធ្ងរនៅពេលកើតមក | បាទ/ចាស \| ទេ |
| កូនរបស់ខ្ញុំមានរោគរលាកស្រោមខួរ | បាទ/ចាស \| ទេ |
| កូនរបស់ខ្ញុំមានជំងឺខាន់លឿង ដែលតម្រូវឱ្យមានការចាក់ប្តូរឈាម | បាទ/ចាស \| ទេ |
| កូនរបស់ខ្ញុំបានទទួលការព្យាបាលនៅកន្លែងថែទាំយ៉ាងយកចិត្តទុកដាក់ ច្រើនជាង៥ថ្ងៃ បន្ទាប់ពីបានកើតមក | បាទ/ចាស \| ទេ |
| ខ្ញុំបានកត់សម្គាល់ឃើញអ្វីមួយដែលមិនប្រក្រតីអំពីក្បាល ឬករបស់កូនខ្ញុំ ដូចជាមានភាពខុសប្លែកពីធម្មតានៃទ្រង់ទ្រាយមុខ ឬសាច់ដុះលើស្បែក | បាទ/ចាស \| ទេ |
| កូនរបស់ខ្ញុំមានជម្ងឺ Down Syndrome (Trisomy 21) ឬរោគផ្សេងទៀត ទាក់ទិននឹងការបាត់បង់សោតវិញ្ញាណ | បាទ/ចាស \| ទេ |

**ប្រសិនបើអ្នកបានគូសរង្វង់យកចម្លើយណាមួយនៅក្នុងជួរដំបូង សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក។**

| **ត្រូវបំពេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាព៖** | **ធម្មតា** | **ពិនិត្យឡើងវិញ** | **បញ្ជូន** |
|---|---|---|---|
| | ☐ | ☐ | ☐ |

## ការពិនិត្យទារកទូទាំងរដ្ឋ - សោតវិញ្ញាណ

SWIS-H
STATEWIDE INFANT
SCREENING - HEARING

ឈ្មោះ

ថ្ងៃខែឆ្នាំកំណើត

**មណ្ឌលសុខភាពក្នុងតំបន់**

| | | |
|---|---|---|
| បានពិនិត្យនៅ | កាលបរិច្ឆេទនៃការពិនិត្យ | |
| ពិនិត្យដោយ (សរសេរឈ្មោះជាអក្សរធំ) | ហត្ថលេខា | |
| **លទ្ធផល** (សូមគូសយកជារង្វង់មូល) | ជាប់ការពិនិត្យ ស្តាំ / បញ្ជូន<br>ជាប់ការពិនិត្យ ឆ្វេង / បញ្ជូន | |
| បញ្ជូនដោយផ្ទាល់ទៅអ្នកសោតទស្សន៍ | ☐ បាទ/ចាស់ | មូលហេតុ: |
| **ធ្វើការពិនិត្យម្តងទៀត** | ☐ **តម្រូវ** | ☐ **មិនតម្រូវ** |
| បានពិនិត្យនៅ | កាលបរិច្ឆេទនៃការពិនិត្យ | |
| ពិនិត្យដោយ (សរសេរឈ្មោះជាអក្សរធំ) | ហត្ថលេខា | |
| **លទ្ធផល** (សូមគូសយកជារង្វង់មូល) | ជាប់ការពិនិត្យ ស្តាំ / បញ្ជូន<br>ជាប់ការពិនិត្យ ឆ្វេង / បញ្ជូន | |
| បញ្ជូនទៅអ្នកសោតទស្សន៍ | ☐ បាទ/ចាស់ | ☐ ទេ |

SWISH មានគោលបំណង ដើម្បីតាមដានរកទារកដែលមានការបាត់បង់សោតវិញ្ញាណយ៉ាងធ្ងន់ធ្ងរនៅវ័យដំបូង។ ការឆែកពិនិត្យសោតវិញ្ញាណត្រូវបានគូសបញ្ជាក់នៅក្នុងសៀវភៅព័ត៌មានសម្រាប់ឪពុកម្តាយ ហេតុអ្វីបានជាកូនរបស់ខ្ញុំត្រូវការការឆែកពិនិត្យសោតវិញ្ញាណ? មានលទ្ធភាពដែលការឆែកពិនិត្យ ប្រហែលជាមិនអាចរកឃើញបញ្ហាសោតវិញ្ញាណដែលមានស្រាប់នោះទេ និង / ឬ ថាកូនរបស់អ្នកអាចមានបញ្ហាសោតវិញ្ញាណនៅពេលក្រោយនៃជីវិត បើទោះជាលទ្ធផលនៃការធ្វើតេស្តនេះគឺជាការធម្មតាក្តី។ សូមបន្តពិនិត្យមើលព្រឹត្តិការណ៍សំខាន់ៗរបស់ទារកអ្នក។ សូមស្វែងរកជំបូន្មានមានពីអ្នកវិជ្ជាជីវៈផ្នែកសុខភាពរបស់អ្នក ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីសោតវិញ្ញាណរបស់កូនអ្នកនៅអាយុណាមួយ។ **(http://www.health.nsw.gov.au/kidsfamilies/MCFhealth/child/pages/hearing-services.aspx)**

**កត្តាហានិភ័យផ្នែកសោតវិញ្ញាណត្រូវបានសម្គាល់ដឹង** ☐ បាទ/ចាស់

នៅពេលអ្នកគូសយកចម្លើយថា បាទ/ចាស់ សូមពិគ្រោះយោបល់ជាមួយអ្នកវិជ្ជាជីវៈផ្នែកសុខភាពរបស់អ្នកដើម្បីរៀបចំឱ្យមានការធ្វើតេស្តសោតវិញ្ញាណសម្រាប់អាយុសមស្រប នៅអាយុ១០-១២ខែ (បានកែ)។

**លេខទូរស័ព្ទអ្នកសម្របសម្រួល៖**

ទៅទំព័រមាតិកា

# ការពិនិត្យសុខភាព
# អាយុ១-៤សប្តាហ៍



# ការគេងដោយសុវត្ថិភាព

សូមចងចាំថា កន្លែងដែលមានសុវត្ថិភាពបំផុតសម្រាប់កូនរបស់អ្នកគេងទាំងយប់ និងថ្ងៃ គឺនៅកន្លែងគេងដែលមានសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។

វិធីប្រាំមួយយ៉ាងដើម្បីឱ្យទារកគេងដោយសុវត្ថិភាព និងដើម្បីកាត់បន្ថយហានិភ័យនៃជំងឺទារកស្លាប់ទាន់ហន់គឺ:

- ដាក់ទារកឱ្យគេងផ្ងារមុខ
- រក្សាដោយកុំគ្របក្បាល និងមុខ
- កុំដាក់ទារកនៅកន្លែងមានផ្សែងបារីមុន និងក្រោយកើតមក
- បរិដ្ឋានគេងពេលយប់ និងថ្ងៃដែលមានសុវត្ថិភាព
- ដាក់ទារកឱ្យគេងនៅក្នុងគ្រែតូចដែលមានសុវត្ថិភាព នៅក្នុងបន្ទប់ដេករបស់ឪពុកម្តាយ
- បំបៅទារកនឹងទឹកដោះ

សម្រាប់ទីកន្លែងដែលអាចរកបានព័ត៌មានបន្ថែម អំពីការគេងដែលមានសុវត្ថិភាព សូមមើលទំព័រ 12។

# ខ្ញុំអាយុ២សប្តាហ៍

## កិច្ចការមួយចំនួនដែលខ្ញុំអាចនឹងធ្វើបាន

- ភ្ញាក់ដោយសូរស័ព្ទខ្លាំង
- ចាប់ផ្តើមសម្លឹងមើលមុខដោយយកចិត្តទុកដាក់
- ក្តាប់ម្រាមដៃអ្នក នៅពេលដាក់មកក្នុងដៃខ្ញុំ

## គំនិតមួយចំនួនសម្រាប់ការចំណាយពេលជាមួយខ្ញុំ

- និយាយមកកាន់ខ្ញុំ ពេលណាខ្ញុំភ្ញាក់ពីគេង
- ឆ្លើយតបទៅនឹងសម្លេង និងពាក្យសម្តីរបស់ខ្ញុំដោយចម្លងតាមអ្វីដែលខ្ញុំធ្វើ
- ឱបរឹតថ្នាក់ថ្នមខ្ញុំ

## សូមនិយាយជាមួយគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ ឬវេជ្ជបណ្ឌិតរបស់ខ្ញុំ ប្រសិនបើខ្ញុំ:

- ពុំមានប្រតិកម្មទៅនឹងសូរសម្លេងខ្លាំង
- ពុំញ៉ាំអាហារបានល្អទេ

សម្រាប់គំនិតបន្ថែមទៀត អំពីការចំណាយពេលវេលាជាមួយខ្ញុំ សូមចូលទៅកាន់: *Love, talk, sing, read, play (ក្តីស្រឡាញ់ និយាយ ច្រៀង អាន លេង)* ធនធាន៖ **www.lovetalksingreadplay.com.au**

មានកំណែនៃប្រូក្រាមនេះសម្រាប់ក្រុមគ្រួសារជនជាតិដើម សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវិបសៃ៖ **http://www.deadlytots.com.au/Page/deadlytotsapp**

# ការទៅពិនិត្យសុខភាពអាយុ១ ទៅ៤សប្តាហ៍

ការទៅពិនិត្យសុខភាពលើកដំបូងរបស់អ្នក ជាមួយគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ តាមធម្មតាធ្វើឡើងនៅក្នុងផ្ទះគ្រួសារ។ នេះជាពេលល្អមួយសម្រាប់ឪពុកម្តាយ និងគិលានុបដ្ឋាកដើម្បីឱ្យបានស្គាល់គ្នា និងនិយាយអំពីការព្រួយបារម្ភណាមួយ។

ប្រធានបទសម្រាប់ការពិភាក្សា អាចរួមមាន:

## សុខភាព និងសុវត្ថិភាព

- ការបញ្ចុកអាហារទារករបស់អ្នក - រួមទាំងការបំបៅនឹងដោះផងដែរ
- ការគេងដែលមានសុវត្ថិភាព និងជំងឺទារកស្លាប់ទាន់ហន់ (SUDI)
- ការចាក់ថ្នាំបង្ការរោគ
- សុវត្ថិភាព
- ការធំលូតលាស់

## ការរីកចម្រើន

- ការស្រែកយំ
- ការលួងលោមចិត្តទារករបស់អ្នក
- ការនិយាយទៅកាន់ទារករបស់អ្នក - ការប្រាស្រ័យទាក់ទង ភាសា និងការលេង

## ក្រុមគ្រួសារ

- ការប្រើប្រាស់ 'កំណត់ត្រាសុខភាពផ្ទាល់ខ្លួន'
- តួនាទីរបស់គិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ GP និងអ្នកវិជ្ជាជីវៈផ្នែកសុខភាពឯទៀត
- សុខភាពផ្លូវចិត្តរបស់ឪពុកម្តាយ
- សុខភាពទូទៅរបស់ម្តាយ - របបអាហារ ការសម្រាក ការថែរក្សាដោះ ការធ្វើលំហាត់ប្រាណ សុខភាពមាត់
- ក្រុម និងបណ្តាញគាំទ្រឪពុកម្តាយ
- ការជក់បារី
- ការងារ / ការថែទាំកុមារ

## តើនៅតែជក់បារីឬ?

ការជក់បារីបង្កើនហានិភ័យនៃជំងឺទារកស្លាប់ទាន់ហន់ (ជំងឺទារកស្លាប់ទាន់ហន់ - SIDS)។

សូមទូរស័ព្ទ **13 QUIT** (13 7848) ឬបើកចូលវ៉ិបសៃ **www.icanquit.com.au**

# សំណួរសម្រាប់ឪពុកម្តាយ / អ្នកថែទាំ

**សូមឆ្លើយសំណួរទាំងនេះ មុនពេលអ្នកទៅជួបគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នកសម្រាប់ការពិនិត្យសុខភាពអាយុ១-៤សប្តាហ៍។**

| | |
|---|---|
| តើអ្នកបានបំពេញសំណួរទាំងឡាយអំពីកត្តាហានិភ័យផ្នែកសុខភាព នៅទំព័រ 21 ហើយឬនៅ? | ទេ \| បាទ/ចាស៎ |
| ខ្ញុំមានការព្រួយបារម្ភអំពីសោតវិញ្ញាណរបស់ទារកខ្ញុំ | បាទ/ចាស៎ \| ទេ |
| អ្នកផ្សេងទៀតបាននិយាយថា ពួកគេមានការព្រួយបារម្ភអំពីសោតវិញ្ញាណរបស់ទារកខ្ញុំ | បាទ/ចាស៎ \| ទេ |
| ខ្ញុំមានការព្រួយបារម្ភអំពីចក្ខុវិញ្ញាណរបស់ទារកខ្ញុំ | បាទ/ចាស៎ \| ទេ |
| ទារករបស់ខ្ញុំមានវេប៉ះពាល់នឹងការជក់បារីនៅក្នុងផ្ទះ ឬរថយន្ត | បាទ/ចាស៎ \| ទេ |
| ខ្ញុំដាក់ទារករបស់ខ្ញុំឱ្យគេងផ្ងារមុខ | ទេ \| បាទ/ចាស៎ |

**ប្រសិនបើអ្នកបានគូសរង្វង់យកចម្លើយណាមួយនៅក្នុងជួរដំបូង សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក។**

| ត្រូវបំពេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាព៖ | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|
| | ☐ | ☐ | ☐ |

## ការបញ្ចុក

| | បាទ/ចាស៎ | ទេ |
|---|---|---|
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានបៅទឹកដោះម្តាយឬទេ? | ☐ | ☐ |
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានទទួលអ្វីមួយដូចតទៅនេះឬទេ? | | |
| ក) វីតាមីន ឬអាហារបន្ថែមជាតិរ៉ែ ឬថ្នាំពេទ្យ (ប្រសិនបើតម្រូវ) | ☐ | ☐ |
| ខ) ទឹកធម្មតា ឬទឹកផ្អែម / ទឹកដាក់រសជាតិ ឬទឹកផ្លែឈើ ឬតែ / ទឹកធុង | ☐ | ☐ |
| គ) ម្សៅទឹកដោះសម្រាប់ទារក ឬទឹកដោះគោផ្សេងទៀត (ឧទាហរណ៍ទឹកដោះគោ ទឹកសណ្តែក ទឹកដោះគោបង្ហូត ទឹកដោះគោខាប់។ល។) | ☐ | ☐ |
| ឃ) អាហាររឹង ឬអាហារទន់ល្មម | ☐ | ☐ |

ការណែនាំបច្ចុប្បន្នគឺថា ទារកត្រូវបំបៅតែទឹកដោះម្តាយប៉ុណ្ណោះរហូតដល់អាយុ៦ខែ (អាចញ៉ាំវីតាមីន ថ្នាំបំប៉នសារធាតុរ៉ែ ឬថ្នាំពេទ្យ) ហើយបន្តបំបៅនឹងទឹកដោះ (ខណៈពេលដែលទទួលអាហារបំពេញបន្ថែមសមស្រប) រហូតដល់អាយុ១២ខែ ឬលើសពីនេះ។ *NHMRC Infant Feeding Guidelines: Information for Health Workers (2012).*

# ការពិនិត្យសុខភាពកុមារអាយុ១ ទៅ៤សប្តាហ៍

ការវាយតម្លៃធ្វើឡើងដោយគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រូសារ GP ឬពេទ្យព្យាបាលកុមារ។

ឈ្មោះ

ថ្ងៃខែឆ្នាំកំណើត / / ភេទ ប / ស

| ការវាយតម្លៃសុខភាព | | | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|---|---|
| ទម្ងន់ | គក្រ | % | ☐ | ☐ | ☐ |
| ប្រវែង | សម | % | ☐ | ☐ | ☐ |
| បរិមាត្រក្បាល | សម | % | ☐ | ☐ | ☐ |
| បង្អើយទារក | | | ☐ | ☐ | ☐ |
| ភ្នែក (ការសង្កេតមើល / ចលនាគ្រាប់ភ្នែក / ប្រស្រីភ្នែកស) | | | ☐ | ☐ | ☐ |
| សរសៃឈាមបេះដូង (វេជ្ជបណ្ឌិតប៉ុណ្ណោះ) | | | ☐ | ☐ | ☐ |
| ផ្ចិត | | | ☐ | ☐ | ☐ |
| ដីពចរក្តៅ | | | ☐ | ☐ | ☐ |
| ការធ្វើតេស្តត្រគាកដើម្បីរកមើលការភ្លាត់ឆ្អឹង | | | ☐ | ☐ | ☐ |
| ពងស្វាសធ្លាក់ចុះទាំងស្រុង ស / ធ | | | ☐ | ☐ | ☐ |
| ប្រដាប់បន្តពូជ | | | ☐ | ☐ | ☐ |
| តំបន់រន្ធគូថ | | | ☐ | ☐ | ☐ |
| ស្បែក | | | ☐ | ☐ | ☐ |
| ភាពញ្ញោច | | | ☐ | ☐ | ☐ |

ទៅទំព័រមាតិកា

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

| កត្តាការពារសុខភាព | បាទ/ចាស៎ | ទេ | ការព្រួយបារម្ភ | ពុំមានការព្រួយបារម្ភ |
|---|---|---|---|---|
| តើបានបំពេញសំណួរសម្រាប់ឪពុកម្តាយហើយឬនៅ? | ☐ | ☐ | ☐ | ☐ |
| តើបានបញ្ចប់ការចាក់ថ្នាំបង្ការរោគសម្រាប់អាយុសមរម្យទៅតាមគម្រោងហើយឬនៅ? (ជំងឺរលាកថ្លើមប្រភេទ B ប៉ុណ្ណោះ) | ☐ | ☐ | | |
| តើមានកត្តាហានិភ័យណាមួយទេ? | | | | |
| សោតវិញ្ញាណ | ☐ | ☐ | | |
| ចក្ខុវិញ្ញាណ | ☐ | ☐ | | |
| ត្រគាក | ☐ | ☐ | | |
| សុខភាពមាត់ | ☐ | ☐ | | |

| លទ្ធផល | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|
| | ☐ | ☐ | ☐ |

**តើមានបានពិភាក្សាព័ត៌មានអំពីសុខភាពសមរម្យហើយឬនៅ?** **បាទ/ចាស៎** ☐ **ទេ** ☐

យោបល់

សកម្មភាពត្រូវបានចាត់វិធានការ

ឈ្មោះរបស់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក

ហត្ថលេខា

ទីកន្លែង កាលបរិច្ឆេទនៃការពិនិត្យ / /

ទៅទំព័រមាតិកា

# ការពិនិត្យសុខភាព
# អាយុ៦-៨សប្តាហ៍



# ការទៅពិនិត្យសុខភាពអាយុ៦-៨សប្តាហ៍

ប្រធានបទសម្រាប់ការពិភាក្សា អាចរួមមានបញ្ហាណាមួយដែលកើតឡើងពី៖

- ការរីកចម្រើនរបស់ខ្ញុំ *(រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។)*
- សំណួរបន្ថែមរបស់ឪពុកម្តាយ / អ្នកថែទាំ
- ការពិនិត្យសុខភាពកុមារ។

## សុខភាព និងសុវត្ថិភាព

- ការបញ្ចុកអាហារទារករបស់អ្នក - រួមទាំងការបំបៅនឹងដោះផងដែរ
- ការចាក់ថ្នាំបង្ការរោគ
- ការគេងដែលមានសុវត្ថិភាព និងជំងឺទារកស្លាប់ទាន់ហន់ (SUDI)
- របៀបការពារកុំឱ្យត្រូវពន្លឺថ្ងៃដែលអាចនាំឱ្យកើតជំងឺមហារីកស្បែក
- ការធំលូតលាស់

## ការរីកចម្រើន

- ការស្រែកយំ
- ការលួងលោមចិត្តទារករបស់អ្នក
- ការនិយាយទៅកាន់ទារករបស់អ្នក - ការប្រាស្រ័យទាក់ទង ភាសា និងការលេងជាគ្រួសារ

## ក្រុមគ្រួសារ

- ក្រុមឪពុកម្តាយ
- សុខភាពរបស់ម្តាយ (របបអាហារ ការសម្រាក ការរៀបចំផែនការគ្រួសារ ការធ្វើលំហាត់ប្រាណ)
- សុខភាពផ្លូវចិត្តរបស់ឪពុកម្តាយ
- ការជក់បារី
- ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន និងការបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយទារករបស់អ្នក

**តើនៅតែជក់បារីឬ?**

ការជក់បារីបង្កើនហានិភ័យនៃជំងឺទារកស្លាប់ទាន់ហន់ (ជំងឺទារកស្លាប់ទាន់ហន់ - SIDS)។

សូមទូរស័ព្ទ **13 QUIT** (13 7848) ឬបើកចូលវ៉ិបសៃ **www.icanquit.com.au**

# ខ្ញុំអាយុ៨សប្តាហ៍

## ការរីកចម្រើនរបស់ខ្ញុំ - *រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។*

(អ្វីដែលទារកភាគច្រើនធ្វើនៅត្រង់អាយុនេះ)

### ផ្នែកសង្គម / ផ្លូវចិត្ត

- ☐ ចាប់ផ្តើមញញឹមដាក់មនុស្ស
- ☐ អាចស្ងប់ស្ងាត់មួយរយៈខ្លីដោយខ្លួនឯង (អាចយកដៃដាក់ចូលទៅមាត់ និងបឺតលើដៃ)
- ☐ ព្យាយាមសម្លឹងមើលឪពុក ឬម្តាយ។

### ភាសា / ការទំនាក់ទំនង

- ☐ និយាយកកែកករជដែលៗ ធ្វើសម្លេង កា-កា-កា
- ☐ បែរក្បាលទៅរកសម្លេង

### ការយល់ដឹង (ការរៀន ការគិត ការដោះស្រាយបញ្ហា)

- ☐ សម្លឹងមើលមុខដោយយកចិត្តទុកដាក់
- ☐ ចាប់ផ្តើមសម្លឹងមើលតាមវត្ថុ ហើយទទួលស្គាល់មនុស្សពីចម្ងាយ
- ☐ ចាប់ផ្តើមធ្វើសកម្មភាពដូចជាអផ្សុក (ស្រែកយំ មួម៉ៅ) ប្រសិនបើមិនផ្លាស់ប្តូរសកម្មភាព

### ការរីកចម្រើនផ្នែកចលនា / រាងកាយ

- ☐ អាចទប់ក្បាលឡើងលើ និងចាប់ផ្តើមយកដៃទាំងពីររុញទប់លើកដងខ្លួន ពេលណាដេកផ្កាប់នៅលើក្បាលពោះ
- ☐ ធ្វើឱ្យមានចលនារលូន ជាមួយដៃ និងជើង

### ចាត់វិធានការឱ្យបានមុនពេល ដោយនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់កូនអ្នក ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ ប្រសិនបើកូនរបស់អ្នក:

- ☐ ពុំឆ្លើយតបទៅនឹងសូរសម្លេងខ្លាំង
- ☐ ពុំមើលវត្ថុនៅពេលវាផ្លាស់ប្តូរទីកន្លែង
- ☐ ពុំញញឹមដាក់មនុស្ស
- ☐ ពុំយកដៃដាក់ទៅមាត់
- ☐ មិនអាចទប់ក្បាលឡើងលើ ពេលណាយកដៃទាំងពីររុញទប់លើកដងខ្លួន នៅពេលដេកលើក្បាលពោះ

---

សម្រាប់គំនិតបន្ថែមទៀត អំពីការចំណាយពេលវេលាជាមួយខ្ញុំ សូមចូលទៅកាន់: *Love, talk, sing, read, play (ក្តីស្រឡាញ់ និយាយ ច្រៀង អាន លេង)* **www.lovetalksingreadplay.com.au**។ ធនធានដែលបានផ្តល់ដោយការផ្តល់ធនធានសម្រាប់ឪពុកម្តាយ។

ភាសាសម្របសម្រួលសម្រាប់ភាសាអង់គ្លេសអូស្ត្រាលីដោយរដ្ឋ NSW Ministry of Health. Original content provided by the U.S. Centers for Disease Control and Prevention's *Learn the Signs. Act Early*. Program (**www.cdc.gov/ActEarly**; June 2017) ខែមិថុនា ឆ្នាំ២០១៧)។

---

# សំណួរបន្ថែមទៀតសម្រាប់ឪពុកម្តាយ / អ្នកថែទាំ

## ឆ្លើយសំណួរទាំងនេះមុនពេលអ្នកទៅជួបគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក សម្រាប់ការពិនិត្យសុខភាពអាយុ៦ ទៅ៨សប្តាហ៍។

| | |
|---|---|
| ខ្ញុំបានពិនិត្យសុខភាពក្រោយពេលសម្រាលកូនរួចហើយ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំក៏ត្រូវបានពិនិត្យមើលរួចហើយដែរ | ទេ \| បាទ/ចាស៎ |
| ខ្ញុំមានការព្រួយបារម្ភអំពីទារករបស់ខ្ញុំ | បាទ/ចាស៎ \| ទេ |
| ខ្ញុំបានបំពេញសំណួរអំពីកត្តាហានិភ័យផ្នែកសុខភាពនៅទំព័រ 21 រួចហើយ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំបែរមុខតម្រង់ទៅកាន់ពន្លឺ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំញញឹមដាក់ខ្ញុំ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំមើលមុខខ្ញុំ និងសម្លឹងមើលចំភ្នែកខ្ញុំ | ទេ \| បាទ/ចាស៎ |
| ខ្ញុំបានកត់សម្គាល់ឃើញថាប្រស្រីភ្នែកមួយ ឬទាំងពីររបស់ទារកខ្ញុំ មានពណ៌ស | បាទ/ចាស៎ \| ទេ |
| ទារករបស់ខ្ញុំ និងខ្ញុំសប្បាយរីករាយនៅជុំជាមួយគ្នា | ទេ \| បាទ/ចាស៎ |
| ខ្ញុំអាន និយាយ និងលេងជាមួយទារករបស់ខ្ញុំ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំមានវេងប៉ះពាល់នឹងការជក់បារីនៅក្នុងផ្ទះ ឬរថយន្ត | បាទ/ចាស៎ \| ទេ |
| ខ្ញុំដាក់ទារករបស់ខ្ញុំឱ្យដេកផ្ងារមុខ | ទេ \| បាទ/ចាស៎ |

**ប្រសិនបើអ្នកបានគូសរង្វង់យកចម្លើយណាមួយនៅក្នុងជួរដំបូង សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក។**

| **ត្រូវបំពេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាព៖** | **ធម្មតា** | **ពិនិត្យឡើងវិញ** | **បញ្ជូន** |
|---|---|---|---|
| | ☐ | ☐ | ☐ |

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

| ការបញ្ចុក | បាទ/ចាស | ទេ |
|---|---|---|
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានបៅទឹកដោះម្ដាយឬទេ ? | ☐ | ☐ |
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានទទួលអ្វីមួយដូចតទៅនេះឬទេ ? | | |
| ក ) វីតាមីន ឬអាហារបន្ថែមជាតិរ៉ែ ឬថ្នាំពេទ្យ ( ប្រសិនបើតម្រូវ ) | ☐ | ☐ |
| ខ ) ទឹកធម្មតា ឬទឹកផ្អែម / ទឹកដាក់រសជាតិ ឬទឹកផ្លែឈើ ឬតែ / ទឹកធុង | ☐ | ☐ |
| គ ) ម្សៅទឹកដោះសម្រាប់ទារក ឬទឹកដោះគោផ្សេងទៀត ( ឧទាហរណ៍ ទឹកដោះគោ ទឹកសណ្ដែក ទឹកដោះគោបង្អួត ទឹកដោះគោខាប់។ល។ ) | ☐ | ☐ |
| ឃ ) អាហាររឹង ឬអាហារទន់ល្មម | ☐ | ☐ |

ការណែនាំបច្ចុប្បន្នគឺថា ទារកត្រូវបំបៅតែទឹកដោះម្ដាយប៉ុណ្ណោះរហូតដល់អាយុ៦ខែ (អាចញ៉ាំវីតាមីន ថ្នាំបំប៉នសារធាតុរ៉ែ ឬថ្នាំពេទ្យ) ហើយបន្តបំបៅនឹងទឹកដោះ (ខណៈពេលដែលទទួលអាហារបំពេញបន្ថែមសមស្រប) រហូតដល់អាយុ១២ខែ ឬលើសពីនេះ។
*NHMRC Infant Feeding Guidelines: Information for Health Workers ( 2012 ).*

**អ្នកអាចមានបំណងចង់និយាយជាមួយគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នកអំពីអារម្មណ៍ខាងផ្លូវចិត្ត និងផ្លូវកាយរបស់អ្នក ហើយអ្នកអាចនឹងមានសំណួរទាំងឡាយអំពីរបៀបល្អបំផុតសម្រាប់ការថែទាំកូនរបស់អ្នក។**

កំណត់ហេតុរបស់ឪពុកម្ដាយ

# ការពិនិត្យសុខភាពកុមារអាយុ៦ ទៅ៨សប្តាហ៍

ការវាយតម្លៃធ្វើឡើងដោយគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រូសារ GP ឬពេទ្យព្យាបាលកុមារ។

ឈ្មោះ

ថ្ងៃខែឆ្នាំកំណើត / / ភេទ ប / ស

| ការវាយតម្លៃសុខភាព | | | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|---|---|
| ទម្ងន់ | គក្រ | % | ☐ | ☐ | ☐ |
| ប្រវែង | សម | % | ☐ | ☐ | ☐ |
| បរិមាត្រក្បាល | សម | % | ☐ | ☐ | ☐ |
| ភ្នែក | ការសង្កេតមើល | | ☐ | ☐ | ☐ |
| | ភាពភ្លោចនៃគ្រាប់ភ្នែកទៅនឹងពន្លឺ | | ☐ | ☐ | ☐ |
| | ការរក្សាភ្នែកឱ្យនៅនឹងថ្កល់ | | ☐ | ☐ | ☐ |
| | ការឆ្លើយតបទៅនឹងការមើលដោយភ្នែកមួយ | | ☐ | ☐ | ☐ |
| | ចលនាភ្នែក | | ☐ | ☐ | ☐ |
| សរសៃឈាមបេះដូង (វេជ្ជបណ្ឌិតប៉ុណ្ណោះ) | | | ☐ | ☐ | ☐ |
| ការធ្វើតេស្តត្រគាកដើម្បីរកមើលការភ្លាត់ឆ្អឹង | | | ☐ | ☐ | ☐ |
| ពងស្វាសធ្លាក់ចុះទាំងស្រុង ស / ធ | | | ☐ | ☐ | ☐ |

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

| **កត្តាការពារសុខភាព** | **បាទ/ចាស៎** | **ទេ** | **ការព្រួយបារម្ភ** | **ពុំមានការព្រួយបារម្ភ** |
|---|---|---|---|---|
| តើបានបំពេញសំណួរសម្រាប់ឪពុកម្តាយហើយឬនៅ? | ☐ | ☐ | ☐ | ☐ |
| តើបានបញ្ចប់ការចាក់ថ្នាំបង្ការរោគសម្រាប់អាយុសមរម្យទៅតាមគម្រោងហើយឬនៅ? | ☐ | ☐ | | |
| តើមានកត្តាហានិភ័យណាមួយទេ? | | | | |
| សោតវិញ្ញាណ | ☐ | ☐ | | |
| ចក្ខុវិញ្ញាណ | ☐ | ☐ | | |
| ត្រគាក | ☐ | ☐ | | |
| សុខភាពមាត់ | ☐ | ☐ | | |

| **លទ្ធផល** | **ធម្មតា** | **ពិនិត្យឡើងវិញ** | **បញ្ជូន** |
|---|---|---|---|
| | ☐ | ☐ | ☐ |

**តើមានបានពិភាក្សាព័ត៌មានអំពីសុខភាពសមរម្យហើយឬនៅ?** **បាទ/ចាស៎** ☐ **ទេ** ☐

យោបល់ ____________________

____________________

សកម្មភាពត្រូវបានចាត់វិធានការ ____________________

____________________

ឈ្មោះរបស់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក ____________________

ហត្ថលេខា ____________________

ទីកន្លែង ____________________ កាលបរិច្ឆេទនៃការពិនិត្យ / /

ទៅទំព័រមាតិកា

# ការចាក់ថ្នាំបង្ការរោគ អាយុ៤ខែ



SAVE THE DATE TO VACCINATE

(រក្សាទុកកាលបរិច្ឆេទ ដើម្បីចាក់ថ្នាំបង្ការរោគ)

# ការចាក់ថ្នាំបង្ការរោគអាយុ៤ខែ

គម្រោងចាក់ថ្នាំបង្ការរោគ រដ្ឋ NSW ណែនាំថាកុមារត្រូវបានចាក់ថ្នាំបង្ការរោគ នៅអាយុដូចខាងក្រោមនេះ៖

- កើតមក
- ៦សប្តាហ៍
- ៤ខែ
- ៦ខែ
- ១២ខែ
- ១៨ខែ
- ៤ឆ្នាំ។

## ប្រ៉ូក្រាម Save the Date to Vaccinate (រក្សាទុកកាលបរិច្ឆេទ ដើម្បីចាក់ថ្នាំបង្ការរោគ)

ហេតុអ្វីអ្នកគួរតែទាញយកប្រ៉ូក្រាម 'Save the Date to Vaccinate'

- វាឥតគិតថ្លៃ និងងាយស្រួលប្រើ។
- ដើម្បីបង្កើតគម្រោងផ្ទាល់ខ្លួនសម្រាប់កូនម្នាក់ៗ។
- វាផ្ញើមកអ្នកនូវការរំលឹកដើម្បីកំណត់ការណាត់ជួប។
- វាផ្តល់នូវព័ត៌មានអំពីចាក់ថ្នាំបង្ការរោគ ដោយគ្រាន់តែប្រើចុងម្រាមដៃរបស់អ្នកប៉ុណ្ណោះ។
- វាផ្តល់ជូនសម្លេងលួងលោម / ស្ងប់ស្ងាត់ដោយឥតគិតថ្លៃ។

ដើម្បីទាញយកប៉ូក្រាម សូមបើកចូល
**www.immunisation.health.nsw.gov.au**



# ខ្ញុំអាយុ៤ខែ

**ទោះបីជាពុំមានគម្រោងការពិនិត្យមើលមើលនៅអាយុ៤ខែក្តី អ្នកគួរទៅជួបវេជ្ជបណ្ឌិតរបស់អ្នក ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារប្រសិនបើអ្នកមានការព្រួយបារម្ភណាមួយ។**

| **ការបញ្ចុក** | **បាទ/ចាស៎** | **ទេ** |
|---|---|---|
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានបៅទឹកដោះម្តាយឬទេ? | ☐ | ☐ |
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានទទួលអ្វីមួយដូចតទៅនេះឬទេ? | | |
| ក) វីតាមីន ឬអាហារបន្ថែមជាតិរ៉ែ ឬថ្នាំពេទ្យ (ប្រសិនបើតម្រូវ) | ☐ | ☐ |
| ខ) ទឹកធម្មតា ឬទឹកផ្អែម / ទឹកដាក់រសជាតិ ឬទឹកផ្លែឈើ ឬតែ / ទឹកធុង | ☐ | ☐ |
| គ) ម្សៅទឹកដោះសម្រាប់ទារក ឬទឹកដោះគោផ្សេងទៀត (ឧទាហរណ៍ ទឹកដោះគោ ទឹកសណ្តែក ទឹកដោះគោបង្ហួត ទឹកដោះគោខាប់។ល។) | ☐ | ☐ |
| ឃ) អាហាររឹង ឬអាហារទន់ល្មម | ☐ | ☐ |

## ការបំបៅកូននឹងដោះ

នេះត្រូវបានណែនាំថា អ្នកត្រូវបំបៅទារករបស់អ្នកនឹងទឹកដោះម្តាយតែប៉ុណ្ណោះ ហើយមិនត្រូវបំបៅជាមួយទឹកដោះគោផ្សេងទៀត អាហារ ឬភេសជ្ជៈណាឡើយរហូតដល់អាយុ៦ខែ។ នៅប្រហែលអាយុ៦ខែ នេះត្រូវបានណែនាំបន្ថែមទៀតថាអ្នកចាប់ផ្តើមបញ្ចុកអាហាររឹង ខណៈពេលបន្តបំបៅនឹងទឹកដោះម្តាយរហូតដល់អាយុ១២ខែ ឬយូរជាងនេះ។ ដើម្បីស្វែងរកព័ត៌មានបន្ថែមអំពីការចាប់ផ្តើមបញ្ចុកអាហារគ្រួសារ សូមមើលទំព័រ 19។



ទៅទំព័រមាតិកា

# ការពិនិត្យសុខភាព

# អាយុ៦ខែ



# ការទៅពិនិត្យសុខភាពអាយុ៦ខែ

ប្រធានបទសម្រាប់ការពិភាក្សា អាចរួមមានបញ្ហាណាមួយដែលកើតឡើងពី៖

- ការរីកចម្រើនរបស់ខ្ញុំ *(រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។)*
- សំណួរបន្ថែមរបស់ឪពុកម្ដាយ / អ្នកថែទាំ
- ការពិនិត្យសុខភាពកុមារ។

## សុខភាព និងសុវត្ថិភាព

- ការគេង
- ការគេងដែលមានសុវត្ថិភាព និងជំងឺទារកស្លាប់ទាន់ហន់ (SUDI)
- ការជួយទារករបស់អ្នកឱ្យញ៉ាំអាហារដែលមានសុខភាពល្អ
- ការថែរក្សាធ្មេញរបស់ទារកអ្នក
- ការចាក់ថ្នាំបង្ការរោគ
- របៀបការពារកុំឱ្យត្រូវពន្លឺថ្ងៃដែលអាចនាំឱ្យកើតជំងឺមហារីកស្បែក
- សុវត្ថិភាព
- ការធំលូតលាស់
- មិនធ្វើអ្វីដែលខ្ញុំធ្លាប់អាចធ្វើបាន

## ក្រុមគ្រួសារ

- ទំនាក់ទំនង និងការប្រជែងគ្នារវាងបងប្អូនបង្កើត
- សកម្មភាពលេង
- សុខភាពផ្លូវចិត្តរបស់ឪពុកម្ដាយ
- ការទៅកន្លែងក្រុមកុមារតូចៗ
- ការជក់បារី
- ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន និងការបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយទារករបស់អ្នក
- បង្ហាញឱ្យឃើញការចង់ដឹងអំពីវត្ថុទាំងឡាយ ហើយព្យាយាមចាប់យកវត្ថុដែលនៅផុតពីដៃ

**តើនៅតែជក់បារីឬ?**

ការជក់បារីបង្កើនហានិភ័យនៃជំងឺទារកស្លាប់ទាន់ហន់ (ជំងឺទារកស្លាប់ទាន់ហន់ - SIDS)។

សូមទូរស័ព្ទ **13 QUIT** (13 7848) ឬបើកចូលវ៉ិបសៃ **www.icanquit.com.au**

# ខ្ញុំអាយុ៦ខែ

## ការរីកចម្រើនរបស់ខ្ញុំ - *រៀនដឹងពីសញ្ញា។ចាត់វិធានការឱ្យបានមុនពេល។*

(អ្វីដែលទារកភាគច្រើនធ្វើនៅត្រង់អាយុនេះ)

### ផ្នែកសង្គម / ផ្លូវចិត្ត

- ☐ ដឹងមុខដែលធ្លាប់ស្គាល់ ហើយចាប់ផ្ដើមដឹងប្រសិនបើនរណាម្នាក់ជាមនុស្សចម្លែក
- ☐ ចូលចិត្តលេងជាមួយអ្នកដទៃ ជាពិសេសឪពុកម្ដាយ
- ☐ ឆ្លើយតបទៅនឹងអារម្មណ៍របស់មនុស្សផ្សេងទៀត ហើយជាញឹកញាប់ហាក់បីដូចជាសប្បាយរីករាយ
- ☐ ចូលចិត្តមើលខ្លួនឯងក្នុងកញ្ចក់

### ភាសា / ការទំនាក់ទំនង

- ☐ ឆ្លើយតបទៅនឹងសម្លេងដោយបញ្ចេញសូរសម្លេង
- ☐ ចងភ្ជាប់ស្រៈរួមគ្នានៅពេលធ្វើសម្លេងកកែកករ ("អា", "អេ", "អូ") និងចូលចិត្តធ្វើតាមវេន ជាមួយឪពុកម្ដាយ ពេលណាធ្វើសម្លេង
- ☐ ឆ្លើយតបពេលណាហៅចំឈ្មោះ
- ☐ ធ្វើសម្លេងដើម្បីបង្ហាញនូវសេចក្ដីអំណរ និងការមិនពេញចិត្ត
- ☐ ចាប់ផ្ដើមនិយាយសម្លេងព្យញ្ជនៈ (និយាយប៉ប៉ោចនឹងសម្លេង "ម", "ប")

### ការយល់ដឹង (ការរៀន ការដោះស្រាយបញ្ហា)

- ☐ មើលជុំវិញវត្ថុទាំងឡាយដែលនៅជុំវិញ
- ☐ ដាក់វត្ថុចូលទៅក្នុងមាត់
- ☐ បង្ហាញឱ្យឃើញការចង់ដឹងអំពីវត្ថុទាំងឡាយ ហើយព្យាយាមចាប់យកវត្ថុដែលនៅផុតពីដៃ
- ☐ ចាប់ផ្ដើមហុចវត្ថុពីដៃមួយ ទៅដៃមួយទៀត

### ការរីកចម្រើនផ្នែកចលនា / រាងកាយ

- ☐ រមៀលខ្លួនចុះឡើងទៅសងខាង (ពីមុខទៅក្រោយ ពីក្រោយទៅមុខ)
- ☐ ចាប់ផ្ដើមអង្គុយដោយគ្មានការគាំទ្រ
- ☐ នៅពេលងើបឈរ ឈរទប់ទម្ងន់លើជើងទាំងពីរ ហើយអាចលោតហក់ចុះឡើង
- ☐ រមៀលខ្លួនចុះឡើង ពេលខ្លះវារថយក្រោយ មុននឹងវារទៅមុខ

***ចាត់វិធានការឱ្យបានមុនពេល*** **ដោយនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់កូនអ្នក ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ ប្រសិនបើកូនរបស់អ្នក:**

- ☐ ពុំព្យាយាមចាប់យកវត្ថុដែលនៅក្បែរដៃ
- ☐ ពុំបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកថែទាំ
- ☐ ពុំឆ្លើយតបទៅនឹងសម្លេងនៅជុំវិញខ្លួន
- ☐ មានការលំបាកក្នុងការដាក់វត្ថុចូលទៅក្នុងមាត់
- ☐ ពុំបញ្ចេញសម្លេងស្រះ (" អា", "អេ", "អូ")
- ☐ ពុំរមៀលខ្លួនចុះឡើងទៅសងខាង
- ☐ ពុំសើច ឬមិនបន្លឺសូរសម្លេងញ៉ៅកៗ
- ☐ ហាក់បីដូចជារឹងខ្លាំងណាស់ ដោយមានសាច់ដុំរឹតតឹង
- ☐ ហាក់បីដូចជាទន់ខ្លាំងណាស់ ដូចជាកូនក្រមុំក្មេងលេងញាត់សាច់ក្រណាត់។

---

សម្រាប់គំនិតបន្ថែមទៀត អំពីការចំណាយពេលវេលាជាមួយខ្ញុំ សូមចូលទៅកាន់: *Love, talk, sing, read, play (ក្តីស្រឡាញ់ និយាយ ច្រៀង អាន លេង)* **www.lovetalksingreadplay.com.au**។ ធនធានដែលបានផ្តល់ដោយការផ្តល់ធនធានសម្រាប់ឪពុកម្តាយ។

ភាសាសម្របសម្រួលសម្រាប់ភាសាអង់គ្លេសអូស្ត្រាលីដោយរដ្ឋ NSW Ministry of Health. Original content provided by the U.S. Centers for Disease Control and Prevention's *Learn the Signs. Act Early.* Program (**www.cdc.gov/ActEarly**; June 2017) ខែមិថុនា ឆ្នាំ២០១៧)។

---

# សំណួរបន្ថែមទៀតសម្រាប់ឪពុកម្តាយ / អ្នកថែទាំ

## សូមឆ្លើយសំណួរទាំងនេះ មុនពេលអ្នកទៅជួបគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក សម្រាប់ការពិនិត្យសុខភាពអាយុ៦ខែ។

| | |
|---|---|
| ខ្ញុំមានការព្រួយបារម្ភអំពីកូនរបស់ខ្ញុំ | បាទ/ចាស៎ | ទេ |
| ខ្ញុំបានបំពេញសំណួរអំពីកត្តាហានិភ័យផ្នែកសុខភាពនៅទំព័រ 21 រួចហើយ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំបែរមុខតម្រង់ទៅកាន់ពន្លឺ | ទេ \| បាទ/ចាស៎ |
| ខ្ញុំបានកត់សម្គាល់ឃើញថាប្រស្រីភ្នែកមួយ ឬទាំងពីររបស់ទារកខ្ញុំ មានពណ៌ស | បាទ/ចាស៎\| ទេ |
| ទារករបស់ខ្ញុំ និងខ្ញុំសប្បាយរីករាយនៅជុំជាមួយគ្នា | ទេ \| បាទ/ចាស៎ |
| ខ្ញុំអាន និយាយ និងលេងជាមួយទារករបស់ខ្ញុំ | ទេ \| បាទ/ចាស៎s |
| ទារករបស់ខ្ញុំមានរងប៉ះពាល់នឹងការជក់បារីនៅក្នុងផ្ទះ ឬរថយន្ត | បាទ/ចាស៎\| ទេ |
| ខ្ញុំដាក់ទារករបស់ខ្ញុំឱ្យដេកផ្ងារមុខ | ទេ \| បាទ/ចាស៎ |

**ប្រសិនបើអ្នកបានគូសរង្វង់យកចម្លើយណាមួយនៅក្នុងជួរដំបូង សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក។**

| ត្រូវបំពេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាព៖ | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|
| | ☐ | ☐ | ☐ |

| **ការបញ្ចុក** | **មិនអាចចាំបាន** | **បាទ/ចាស** | **ទេ** |
|---|---|---|---|
| នៅពេលទារករបស់អ្នកមាន**អាយុ៤ខែ** តើវាបានបៅទឹកដោះម្ដាយឬទេ? (អ្នកប្រហែលជាបានឆ្លើយសំណួរនេះ នៅក្នុងផ្ទាំងការចាក់ថ្នាំបង្ការពេលអាយុ៤ខែ)? | ☐ | ☐ | ☐ |
| ចាប់តាំងពី**ម្សិលមិញពេលនេះ** តើទារករបស់អ្នកបានបៅទឹកដោះម្ដាយឬទេ? | ☐ | ☐ | ☐ |
| ចាប់តាំង**ពីម្សិលមិញពេលនេះ** តើទារករបស់អ្នកបានទទួលអ្វីមួយដូចតទៅនេះឬទេ? | | | |
| ក) វីតាមីន ឬអាហារបន្ថែមជាតិរ៉ែ ឬថ្នាំពេទ្យ (ប្រសិនបើតម្រូវ) | ☐ | ☐ | ☐ |
| ខ) ទឹកធម្មតា ឬទឹកផ្អែម / ទឹកដាក់រសជាតិ ឬទឹកផ្លែឈើ ឬតែ / ទឹកធុង | ☐ | ☐ | ☐ |
| គ) ម្សៅទឹកដោះសម្រាប់ទារក ឬទឹកដោះគោផ្សេងទៀត (ឧទាហរណ៍ ទឹកដោះគោ ទឹកសណ្ដែក ទឹកដោះគោបង្ហួត ទឹកដោះគោខាប់។ល។) | ☐ | ☐ | ☐ |
| ឃ) អាហាររឹង ឬអាហារទន់ល្មម | ☐ | ☐ | ☐ |

---

ការណែនាំបច្ចុប្បន្នគឺថា ទារកត្រូវបំបៅតែទឹកដោះម្ដាយប៉ុណ្ណោះរហូតដល់អាយុ៦ខែ (អាចញ៉ាំវីតាមីន ថ្នាំបំប៉នសារធាតុរ៉ែ ឬថ្នាំពេទ្យ) ហើយបន្តបំបៅនឹងទឹកដោះ (ខណៈពេលដែលទទួលអាហារបំពេញបន្ថែមសមស្រប) រហូតដល់អាយុ១២ខែ ឬលើសពីនេះ។
*NHMRC Infant Feeding Guidelines: Information for Health Workers (2012).*

---

## ការពិនិត្យសុខភាពកុមារអាយុ៦ខែ

ការវាយតម្លៃធ្វើឡើងដោយគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រូសារ GP ឬពេទ្យព្យាបាលកុមារ។

ឈ្មោះ

ថ្ងៃខែឆ្នាំកំណើត / / ភេទ ប / ស

| ការវាយតម្លៃសុខភាព | | | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|---|---|
| ទម្ងន់ | គក្រ | % | ☐ | ☐ | ☐ |
| ប្រវែង | សម | % | ☐ | ☐ | ☐ |
| បរិមាត្រក្បាល | សម | % | ☐ | ☐ | ☐ |
| ភ្នែក | ការសង្កេតមើល | | ☐ | ☐ | ☐ |
| | ភាពភ្លោចនៃគ្រាប់ភ្នែកទៅនឹងពន្លឺ | | ☐ | ☐ | ☐ |
| | ការរក្សាភ្នែកឱ្យនៅនឹងថ្កល់ | | ☐ | ☐ | ☐ |
| | ការឆ្លើយតបទៅនឹងការមើលដោយភ្នែកមួយ | | ☐ | ☐ | ☐ |
| | ចលនាភ្នែក | | ☐ | ☐ | ☐ |
| ការពិនិត្យសុខភាពមាត់ដោយ "ហើបបបូរមាត់" | | | ☐ | ☐ | ☐ |
| ការធ្វើតេស្តត្រគាកដើម្បីរកមើលការភ្លាត់ឆ្អឹង | | | ☐ | ☐ | ☐ |
| ពងស្វាសធ្លាក់ចុះទាំងស្រុង ស / ធ | | | ☐ | ☐ | ☐ |

ទៅទំព័រមាតិកា

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

| **កត្តាការពារសុខភាព** | **បាទ/ចាស៎** | **ទេ** | **ការព្រួយបារម្ភ** | **ពុំមានការព្រួយបារម្ភ** |
|---|---|---|---|---|
| តើបានបំពេញប្រវត្តិសុខភាពគ្រួសារ និងកត្តាហានិភ័យហើយឬនៅ? | ☐ | ☐ | ☐ | ☐ |
| **តើបានបំពេញសំណួរសម្រាប់ឪពុកម្ដាយហើយឬនៅ?** | ☐ | ☐ | ☐ | ☐ |
| តើបានបញ្ចប់ការចាក់ថ្នាំបង្ការរោគសម្រាប់អាយុសមរម្យទៅតាមគម្រោងហើយឬនៅ? | ☐ | ☐ | ☐ | ☐ |
| តើមានកត្តាហានិភ័យណាមួយទេ? | | | | |
| សោតវិញ្ញាណ | ☐ | ☐ | | |
| ចក្ខុវិញ្ញាណ | ☐ | ☐ | | |
| ត្រគាក | ☐ | ☐ | | |
| សុខភាពមាត់ | ☐ | ☐ | | |

| **លទ្ធផល** | **ធម្មតា** | **ពិនិត្យឡើងវិញ** | **បញ្ជូន** |
|---|---|---|---|
| | ☐ | ☐ | ☐ |

**តើមានបានពិភាក្សាព័ត៌មានអំពីសុខភាពសមរម្យហើយឬនៅ?** **បាទ/ចាស៎** ☐ **ទេ** ☐

យោបល់

សកម្មភាពត្រូវបានចាត់វិធានការ

ឈ្មោះរបស់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក

ហត្ថលេខា

ទីកន្លែង កាលបរិច្ឆេទនៃការពិនិត្យ / /

## ធ្មេញរបស់កូនអ្នក - រក្សាវាឱ្យមានសុខភាពល្អ

ធ្មេញមានសុខភាពល្អ គឺមានសារៈសំខាន់សម្រាប់សុខភាពទូទៅ និងការរីកចម្រើនផ្នែកនិយាយស្ដី។ បញ្ហាធ្មេញភាគច្រើនអាចការពារបាន។ ការសម្គាល់ដឹងទាន់ពេល ចំពោះហានិភ័យនៃជំងឺធ្មេញ និងការរកឃើញជំងឺបានមុនពេល អាចការពារការបំផ្លាញរីករាលដាលដល់ធ្មេញ និងការព្យាបាលធ្មេញដែលអស់តម្លៃច្រើនក្នុងមន្ទីរពេទ្យក្រោមការប្រើថ្នាំសន្លប់ទូទៅ។

ដោយឆ្លើយទៅនឹងសំណួរអំពីធ្មេញនៅក្នុងសៀវភៅនេះ អ្នកអាចជួយសម្គាល់ដឹងបញ្ហាដ៏មានសក្តានុពលណាមួយ និងរៀនដឹងពីរបៀបថែទាំធ្មេញរបស់កូនអ្នកឱ្យបានត្រឹមត្រូវ។

### តើធ្មេញទារកដុះចេញមកនៅពេលណា?

| លំដាប់នៃការដុះចេញធ្មេញធម្មតា | ឈ្មោះធ្មេញ | ធ្មេញដុះចេញមកក្នុងអាយុប្រហែលជា |
|---|---|---|
| ១,២,៣,៤ | ធ្មេញមុខ | ៦-១២ខែ |
| ៥,៦ | ធ្មេញថ្គាមដំបូងរបស់ទារក | ១២-២០+ ខែ |
| ៧,៨ | ធ្មេញចង្កូម | ១៨-២៤ខែ |
| ៩,១០ | ធ្មេញថ្គាមទីពីររបស់ទារក | ២៤-៣០ខែ |




*អាយុមធ្យមខាងលើនេះ គ្រាន់តែជាសេចក្ដីណែនាំប៉ុណ្ណោះ។ សូមកុំព្រួយបារម្ភ បើធ្មេញរបស់កូនអ្នកដុះចេញមុន ឬក្រោយអាយុទាំងនេះ។*

### ដបបំបៅ និងក្បាលដោះកៅស៊ូ

ទឹកដោះម្ដាយ គឺជាអាហារល្អបំផុតសម្រាប់ទារករបស់អ្នក។ ប្រសិនបើកូនរបស់អ្នកពុំបំបៅនឹងដោះទេ៖

- ដាក់ទឹកដោះម្ដាយ ម្សៅទឹកដោះសម្រាប់ទារក ឬទឹក**តែប៉ុណ្ណោះ**នៅក្នុងដបរបស់ទារកអ្នក
- ត្រូវលើកបីទាររបស់ជានិច្ចនៅពេលដាក់បំបៅ និងយកដបចេញនៅពេលទាររបស់អ្នកបំបៅឆ្អែត
- ការដាក់ទារករបស់អ្នកឱ្យដេកបៀមដប ដែលអាចបង្កឱ្យធ្មេញពុក (ដង្កូវស៊ីធ្មេញ)
- ការដាក់ទឹកឃ្មុំ glycerine (គ្លីសេរីន) ទឹកដោះគោខាប់ ឬវត្ថុរាវស្អិតផ្អែមផ្សេងទៀតជាប់នៅលើក្បាលដោះកៅស៊ូអាចបង្កឱ្យធ្មេញពុក (ដង្កូវស៊ីធ្មេញ)
- ចាប់ពីអាយុ៦ខែទៅ កុមារភាគច្រើនអាចរៀនអនុវត្តប្រើពែង - ហើយនៅអាយុប្រហែល១២ខែ សូមប្រើពែងជំនួសដបវិញ។

## ការដុះធ្មេញ

- ប្រសិនបើកូនរបស់អ្នកពុំសុខស្រួលនៅពេលដុះធ្មេញ សូមឱ្យកងតូចមួយសម្រាប់ខាំនៅពេលដុះធ្មេញ ឬក្រណាត់ជូតត្រជាក់។
- ប្រសិនបើមានរោគសញ្ញាឯទៀត សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ ។

## អាហារ និងភេសជ្ជៈ

- ផ្តល់អាហារដែលមានសុខភាពល្អ និងអាហារក្រៅពេលចាប់ពីអាយុប្រហែល៦ខែទៅ។
- កុំដាក់ជាតិផ្អែមទៅក្នុងអាហាររបស់ទារក។
- ទឹកម៉ាស៊ីន (ដាំឱ្យពុះ បន្ទាប់មកទុកវាឱ្យត្រជាក់ រហូតទារកមានអាយុ១២ខែ) គឺជាភេសជ្ជៈល្អបំផុតសម្រាប់ផឹករវាងពេលញ៉ាំអាហារ និងពេលចូលគេង។
- ទុកអាហារពិសេស បង្អែមក្រៅពេល និងភេសជ្ជៈ សម្រាប់តែពេលពិសេសប៉ុណ្ណោះ។

## ដំបូន្មានសំខាន់ៗសម្រាប់ការដុសធ្មេញ

- រក្សាធ្មេញ និងអញ្ចាញធ្មេញផ្ទាល់ខ្លួនរបស់អ្នកឱ្យបានស្អាត និងមានសុខភាពល្អ។ មេរោគពីមាត់របស់អ្នកអាចឆ្លងទៅមាត់ទារករបស់អ្នកតាមរយៈក្បាលដោះកៅស៊ូ ដប និងស្លាបព្រា។
- កាលណាធ្មេញដំបូងរបស់កូនអ្នកលេចចេញមកហើយ សូមសម្អាតវាដោយប្រើច្រាសដុសធ្មេញទន់ទំហំសម្រាប់កូនក្មេង ប៉ុន្តែដោយមិនប្រើថ្នាំដុសធ្មេញ។
- ចាប់ពីអាយុ១៨ខែទៅ សូមសំអាតធ្មេញកូនរបស់អ្នកពីរដងក្នុងមួយថ្ងៃ ដោយប្រើថ្នាំដុសធ្មេញមានជាតិហ្លុយអ័រកម្លាំងខ្សោយ ចំនួនទំហំប៉ុនគ្រាប់សណ្តែក។ ប្រើច្រាសដុសធ្មេញទន់ទំហំសម្រាប់កូនក្មេង គួរតែស្តោះវាចោល ប៉ុន្តែមិនត្រូវលេបចូល ហើយកុំខ្ពុរលាងជម្រះមាត់។
- អាចណែនាំឱ្យប្រើថ្នាំដុសធ្មេញមុនពេល ដោយផ្អែកលើដំបូន្មានរបស់អ្នកវិជ្ជាជីវៈផ្នែកសុខភាពដែលបានបណ្តុះបណ្តាលអំពីសុខភាពមាត់ ឬអ្នកវិជ្ជាជីវៈផ្នែកសុខភាពមាត់។
- មនុស្សពេញវ័យគួរប្រើថ្នាំដុសធ្មេញសម្រាប់កុមារអាយុក្រោម៦ឆ្នាំ ហើយរក្សាទុកថ្នាំដុសធ្មេញឱ្យផុតពីដៃកុមារ។



- ចាប់ពីអាយុប្រហែល៣ឆ្នាំទៅ កូនក្មេងអាចប្រើច្រាស់ដុសធ្មេញមួយចំនួនដោយខ្លួនឯង ប៉ុន្តែពួកគេនៅតែត្រូវការជំនួយពីមនុស្សពេញវ័យដើម្បីដុសធ្មេញរបស់ពួកគេ រហូតដល់ពួកគេគឺមានអាយុប្រហែល៧ឆ្នាំទៅ៨ឆ្នាំ។
- រកមើលសញ្ញាដំបូងនៃការពុកធ្មេញ (ដង្កូវស៊ីធ្មេញ) - គឺស្នាមអុចៗពណ៌ស ឬពណ៌ត្នោតដែលពុំបានដុសចេញដោយច្រាស។ ស្វែងរកដំបូន្មានផ្នែកវិជ្ជាជីវៈឱ្យបានឆាប់ តាមលទ្ធភាពធ្វើបាន។
- ចូរប្រាកដថា កូនរបស់អ្នកទទួលការវាយតម្លៃអំពីមានហានិភ័យនៃសុខភាពមាត់ ដែលចាត់ចែងឡើងដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាពដែលបានបណ្តុះបណ្តាលអំពីសុខភាពមាត់ ឬអ្នកវិជ្ជាជីវៈផ្នែកសុខភាពមាត់ឱ្យបានទាន់ថ្ងៃខួបកំណើតលើកទីមួយរបស់ពួកគេ។

ទៅទំព័រមាតិកា

# ការពិនិត្យសុខភាព
# អាយុ១២ខែ



# ការទៅពិនិត្យសុខភាពអាយុ១២ខែ

ប្រធានបទសម្រាប់ការពិភាក្សា អាចរួមមានបញ្ហាណាមួយដែលកើតឡើងពី៖

- ការរីកចម្រើនរបស់កូនរបស់ខ្ញុំ *(រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។)*
- សំណួរឪពុកម្តាយបន្ថែមទៀត
- ការពិនិត្យសុខភាពកុមារ។

## សុខភាព និងសុវត្ថិភាព

- ការញ៉ាំដែលមានសុខភាពល្អ / ការលើកទឹកចិត្តដល់ការលេងដែលសកម្ម
- របៀបថែរក្សាធ្មេញរបស់កូនអ្នក
- ការគេង
- ការចាក់ថ្នាំបង្ការរោគ
- សុវត្ថិភាព
- របៀបការពារកុំឱ្យត្រូវពន្លឺថ្ងៃដែលអាចនាំឱ្យកើតជំងឺមហារីកស្បែក
- ការធំលូតលាស់

## ក្រុមគ្រួសារ

- ទំនាក់ទំនង និងការប្រជែងគ្នារវាងបងប្អូនបង្កើត
- ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន និងការបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយទារករបស់អ្នក
- សុខភាពផ្លូវចិត្តរបស់ឪពុកម្តាយ
- ការជក់បារី
- ការទៅកន្លែងក្រុមកុមារតូចៗ ឬកន្លែងមើលថែកុមារ

## តើនៅតែជក់បារីឬ?

ការជក់បារីបង្កើនហានិភ័យនៃជំងឺទារកស្លាប់ទាន់ហន់ (ជំងឺទារកស្លាប់ទាន់ហន់ - SIDS)។

សូមទូរស័ព្ទ **13 QUIT** (13 7848) ឬបើកចូលវិបសៃ **www.icanquit.com.au**

# ខ្ញុំអាយុ១២ខែ

## ការរីកចម្រើនរបស់ខ្ញុំ - *រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។*

(អ្វីដែលកុមារភាគច្រើនធ្វើនៅអាយុនេះ)

### ផ្នែកសង្គម / ផ្លូវចិត្ត

- ☐ ខ្មាស់អៀន ឬភ័យខ្លាំងជាមួយនឹងមនុស្សចម្លែក
- ☐ ស្រែកយំនៅពេលម្តាយ ឬឪពុកចាកចេញពីគេ
- ☐ មានវត្ថុ និងមនុស្សដែលគេចូលចិត្ត
- ☐ បង្ហាញពីការភ័យខ្លាចនៅក្នុងស្ថានភាពមួយចំនួន
- ☐ ហុចសៀវភៅមកឱ្យអ្នក ពេលណាគេចង់ស្តាប់រឿងអ្វីមួយ
- ☐ បញ្ចេញសម្លេង ឬធ្វើសកម្មឡើងវិញដើម្បីទទួលបានការយកចិត្តទុកដាក់
- ☐ លាតចេញដៃ ឬជើងដើម្បីឱ្យអ្នកជួយស្លៀកពាក់
- ☐ លេងល្បែងទាំងឡាយដូចជា "ល្បែងបិទពួនមុខ" "peek-a-boo" និង "pat-a-cake"

### ភាសា / ការទំនាក់ទំនង

- ☐ ឆ្លើយតបទៅនឹងសំណើនិយាយសាមញ្ញ
- ☐ ប្រើកាយវិការសាមញ្ញ ដូចជាការគ្រវីក្បាល "ទេ" ឬការបក់គ្រវីដៃ "លាហើយ"
- ☐ ធ្វើសូរសម្លេងដោយមានការផ្លាស់ប្តូរសម្លេង (ស្តាប់ទៅដូចជាការនិយាយស្តី)
- ☐ និយាយថា "ម៉ាម៉ា" និង "ប៉ាប៉ា" និងការលាន់មាត់ដូច "អុ អូហ៍"
- ☐ ព្យាយាមនិយាយពាក្យដែលអ្នកនិយាយ

### ការយល់ដឹង (ការរៀន ការគិត ការដោះស្រាយបញ្ហា)

- ☐ រុករកវត្ថុនៅក្នុងវិធីផ្សេងគ្នា ដូចជាអង្រន់ វាយគោះ បោះ
- ☐ រកឃើញវត្ថុដែលបានលាក់យ៉ាងងាយស្រួល
- ☐ មើលទៅចំរូបភាព ឬវត្ថុបានត្រឹមត្រូវពេលណាហៅចំឈ្មោះ
- ☐ ធ្វើតាមកាយវិការ
- ☐ ចាប់ផ្តើមប្រើប្រាស់វត្ថុបានត្រឹមត្រូវ។ ឧទាហរណ៍ ផឹកកេសជ្ជៈចេញពីពែង សិតសក់
- ☐ យកវត្ថុពីរវាយជំនឹងគ្នា
- ☐ ដាក់វត្ថុចូលទៅក្នុងធុង យកវត្ថុចេញពីធុង
- ☐ ប្រលែងវត្ថុចេញពីដៃដោយគ្មានជំនួយ
- ☐ ព្រួចង្អុលដោយប្រើម្រាមដៃចង្អុល
- ☐ ធ្វើតាមការណែនាំសាមញ្ញ ដូចជា «រើសយកប្រដាប់ក្មេងលេង»

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

## ការរីកចម្រើនផ្នែកចលនា / រាងកាយ

- □ ដើបអង្គុយដោយគ្មានជំនួយ
- □ វារតោង ដើរកាន់គ្រឿងសង្ហារឹម ("រុញដើរ")
- □ បោះជំហានមួយចំនួនដោយពុំបាច់កាន់តោងវត្ថុ
- □ អាចក្រោកឈរដោយខ្លួនឯង

## ចាត់វិធានការឱ្យបានមុនពេល ដោយនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់កូនអ្នក ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសារ ប្រសិនបើកូនរបស់អ្នក:

- □ ពុំលូនវារ
- □ ពុំអាចក្រោកឈរនៅពេលមានគេជួយ
- □ ពុំស្វែងរកវត្ថុពេលណាឃើញអ្នកលាក់វត្ថុនោះ
- □ ពុំនិយាយពាក្យមួយម៉ាត់ទាល់តែសោះ ដូចជា "ម៉ាម៉ា" ឬ "ប៉ាប៉ា"
- □ ពុំរៀនចេះកាយវិការទាំងឡាយ ដូចបក់គ្រវីដៃ ឬគ្រវីក្បាល
- □ ពុំចង្អុលទៅកាន់វត្ថុ
- □ បាត់បង់ជំនាញដែលធ្លាប់មានពីមុនៗ។

---

សម្រាប់គំនិតបន្ថែមទៀត អំពីការចំណាយពេលវេលាជាមួយខ្ញុំ សូមចូលទៅកាន់: *Love, talk, sing, read, play (ក្តីស្រឡាញ់ និយាយ ច្រៀង អាន លេង)* **www.lovetalksingreadplay.com.au**។ ធនធានដែលបានផ្តល់ដោយការផ្តល់ធនធានសម្រាប់ឪពុកម្តាយ។

ភាសាសម្របសម្រួលសម្រាប់ភាសាអង់គ្លេសអូស្ត្រាលីដោយរដ្ឋ NSW Ministry of Health. Original content provided by the U.S. Centers for Disease Control and Prevention's *Learn the Signs. Act Early.* Program (**www.cdc.gov/ActEarly**; June 2017) ខែមិថុនា ឆ្នាំ២០១៧)។

---

# សំណួរបន្ថែមទៀតសម្រាប់ឪពុកម្តាយ / អ្នកថែទាំ

## សូមឆ្លើយសំណួរទាំងនេះ មុនពេលអ្នកទៅជួបគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក សម្រាប់ការពិនិត្យសុខភាពអាយុ១២ខែ។

| | |
|---|---|
| ខ្ញុំបានបំពេញសំណួរអំពីកត្តាហានិភ័យផ្នែកសុខភាពនៅទំព័រ 21 រួចហើយ | ទេ \| បាទ/ចាស៎ |
| ខ្ញុំមានការព្រួយបារម្ភអំពីសោតវិញ្ញាណរបស់កូនខ្ញុំ | បាទ/ចាស៎ \| ទេ |
| អ្នកផ្សេងទៀតបាននិយាយថា ពួកគេមានការព្រួយបារម្ភអំពីសោតវិញ្ញាណរបស់កូនខ្ញុំ | បាទ/ចាស៎ \| ទេ |
| ខ្ញុំមានការព្រួយបារម្ភអំពីចក្ខុវិញ្ញាណរបស់កូនខ្ញុំ | បាទ/ចាស៎ \| ទេ |
| កូនរបស់ខ្ញុំមានភ្នែកស្រឡេវ ឬភ្នែកព្រឹមៗ (ភ្នែកស្រលៀង) | បាទ/ចាស៎ \| ទេ |
| កូនរបស់ខ្ញុំមានការលំបាកក្នុងការមើលឃើញវត្ថុតូចៗ | បាទ/ចាស៎ \| ទេ |
| កូនរបស់ខ្ញុំទទួលស្គាល់វត្ថុ និងមនុស្សដែលធ្លាប់ស្គាល់ពីចម្ងាយ | ទេ \| បាទ/ចាស៎ |
| ទារករបស់ខ្ញុំមានរងប៉ះពាល់នឹងការជក់បារីនៅក្នុងផ្ទះ ឬរថយន្ត | បាទ/ចាស៎ \| ទេ |
| កូនរបស់ខ្ញុំមានដុះធ្មេញ | ទេ \| បាទ/ចាស៎ |
| កូនរបស់ខ្ញុំមានបញ្ហាជាមួយនឹងធ្មេញ ឬការដុះធ្មេញ | បាទ/ចាស៎ \| ទេ |
| កូនរបស់ខ្ញុំប្រើដបបំបៅដើម្បីជួយឱ្យអាចគេងលក់ | បាទ/ចាស៎ \| ទេ |
| កូនរបស់ខ្ញុំដើរជុំវិញដោយបៀមដប ឬបៀមពែងបំបៅរវាងការញ៉ាំអាហារ | បាទ/ចាស៎ \| ទេ |
| ខ្ញុំដុសធ្មេញឱ្យកូនរបស់ខ្ញុំ ពីរដងក្នុងមួយថ្ងៃ | ទេ \| បាទ/ចាស៎ |

## ប្រសិនបើអ្នកបានគូសរង្វង់យកចម្លើយណាមួយនៅក្នុងជួរដំបូង សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រួសាររបស់អ្នក។

| ត្រូវបំពេញដោយអ្នកវិជ្ជាជីវៈផ្នែកសុខភាព៖ | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|
| | ☐ | ☐ | ☐ |

| ## ការបំបៅ | បាទ/ចាស | ទេ |
|---|---|---|
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានបៅទឹកដោះម្ដាយឬទេ? | ☐ | ☐ |
| ចាប់តាំងពីម្សិលមិញពេលនេះ តើទារករបស់អ្នកបានញ៉ាំអាហាររឹងឬទេ? | ☐ | ☐ |

---

ការណែនាំបច្ចុប្បន្នគឺថា ទារកត្រូវបំបៅតែទឹកដោះម្ដាយប៉ុណ្ណោះរហូតដល់អាយុ៦ខែ (អាចញ៉ាំវីតាមីន ថ្នាំបំប៉នសារធាតុរ៉ែ ឬថ្នាំពេទ្យ) ហើយបន្តបំបៅនឹងទឹកដោះ (ខណៈពេលដែលទទួលអាហារបំពេញបន្ថែមសមស្រប) រហូតដល់អាយុ១២ខែ ឬលើសពីនេះ។

*NHMRC Infant Feeding Guidelines: Information for Health Workers (2012).*

---

# ការពិនិត្យសុខភាពកុមារអាយុ១២ខែ

ការវាយតម្លៃធ្វើឡើងដោយគិលានុបដ្ឋាកផ្នែកសុខភាពកុមារ និងគ្រូសារ GP ឬពេទ្យព្យាបាលកុមារ។

ឈ្មោះ

ថ្ងៃខែឆ្នាំកំណើត / / ភេទ ប / ស

| ការវាយតម្លៃសុខភាព | | | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|---|---|
| ទម្ងន់ | គក្រ | % | ☐ | ☐ | ☐ |
| កម្ពស់ | សម | % | ☐ | ☐ | ☐ |
| បរិមាត្រក្បាល | សម | % | ☐ | ☐ | ☐ |
| ភ្នែក | ការសង្កេតមើល | | ☐ | ☐ | ☐ |
| | ភាពភ្លោចនៃគ្រាប់ភ្នែកទៅនឹងពន្លឺ | | ☐ | ☐ | ☐ |
| | ការរក្សាភ្នែកឱ្យនៅនឹងថ្កល់ | | ☐ | ☐ | ☐ |
| | ការឆ្លើយតបទៅនឹងការមើលដោយភ្នែកមួយ | | ☐ | ☐ | ☐ |
| | ចលនាភ្នែក | | ☐ | ☐ | ☐ |
| ការពិនិត្យសុខភាពមាត់ដោយ "ហើបបបូរមាត់" | | | ☐ | ☐ | ☐ |
| វាយតម្លៃដំណើរដើរ (ប្រសិនបើកំពុងដើរ) | | | ☐ | ☐ | ☐ |
| ពងស្វាសធ្លាក់ចុះទាំងស្រុង ស / ធ ប្រសិនបើមិនបានពិនិត្យមើលពីមុនទេ | | | ☐ | ☐ | ☐ |

ទៅទំព័រមាតិកា

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

| កត្តាការពារសុខភាព | បាទ/ចាស៎ | ទេ | ការព្រួយបារម្ភ | ពុំមានការព្រួយបារម្ភ |
|---|---|---|---|---|
| តើបានបំពេញសំណួរសម្រាប់ឪពុកម្ដាយហើយឬនៅ? | ☐ | ☐ | ☐ | ☐ |
| តើបានបញ្ចប់ការចាក់ថ្នាំបង្ការរោគសម្រាប់អាយុសមរម្យទៅតាមគម្រោងហើយឬនៅ? | ☐ | ☐ | | |
| តើមានកត្តាហានិភ័យណាមួយទេ? | | | | |
| សោតវិញ្ញាណ | ☐ | ☐ | | |
| ចក្ខុវិញ្ញាណ | ☐ | ☐ | | |
| ត្រគាក | ☐ | ☐ | | |
| សុខភាពមាត់ | ☐ | ☐ | | |

| លទ្ធផល | ធម្មតា | ពិនិត្យឡើងវិញ | បញ្ជូន |
|---|---|---|---|
| | ☐ | ☐ | ☐ |

**តើមានបានពិភាក្សាព័ត៌មានអំពីសុខភាពសមរម្យហើយឬនៅ?** **បាទ/ចាស៎** ☐ **ទេ** ☐

យោបល់

សកម្មភាពត្រូវបានចាត់វិធានការ

ឈ្មោះរបស់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក

ហត្ថលេខា

ទីកន្លែង កាលបរិច្ឆេទនៃការពិនិត្យ / /

# ការពិនិត្យសុខភាព
# អាយុ១៨ខែ



# ការទៅពិនិត្យសុខភាពអាយុ១៨ខែ

ប្រធានបទសម្រាប់ការពិភាក្សា អាចរួមមានបញ្ហាណាមួយដែលកើតឡើងពី៖

- ការរីកចម្រើនរបស់ខ្ញុំ *(រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។)*
- សំណួរបន្ថែមរបស់ឪពុកម្តាយ / អ្នកថែទាំ
- ការពិនិត្យសុខភាពកុមារ។

## សុខភាព និងសុវត្ថិភាព

- ការញ៉ាំដែលមានសុខភាពល្អសម្រាប់គ្រួសារ
- ការគេង
- ការថែរក្សាធ្មេញរបស់កូនអ្នក
- របៀបការពារកុំឱ្យត្រូវពន្លឺថ្ងៃដែលអាចនាំឱ្យកើតជំងឺមហារីកស្បែក
- ការធំលូតលាស់
- ការចាក់ថ្នាំបង្ការរោគ

## ការរីកចម្រើន

- ឥរិយាបថរបស់កូនរបស់អ្នក
- ការចាប់ផ្តើមបង្ហាត់ទៅបង្គន់
- ការលើកទឹកចិត្តដល់ការលេងដែលសកម្ម

## ក្រុមគ្រួសារ

- បញ្ហាបងប្អូនបង្កើត
- ការចិញ្ចឹមបីបាច់កូនដោយវិជ្ជមាន និងការជួយកូនរបស់អ្នកគ្រប់គ្រងអារម្មណ៍ និងអាកប្បកិរិយារបស់ខ្លួន
- ការទៅកន្លែងក្រុមកុមារតូចៗ ឬកន្លែងមើលថែកុមារ
- ការជក់បារី

## តើនៅតែជក់បារីឬ?

ការជក់បារីបង្កើនហានិភ័យនៃជំងឺទារកស្លាប់ទាន់ហន់ (ជំងឺទារកស្លាប់ទាន់ហន់ - SIDS)។

សូមទូរស័ព្ទ **13 QUIT** (13 7848) ឬបើកចូលវិបសៃ **www.icanquit.com.au**

# ខ្ញុំអាយុ១៨ខែ

## ការរីកចម្រើនរបស់ខ្ញុំ - *រៀនដឹងពីសញ្ញា។ ចាត់វិធានការឱ្យបានមុនពេល។*

(អ្វីដែលកុមារភាគច្រើនធ្វើនៅអាយុនេះ)

### ផ្នែកសង្គម / ផ្លូវចិត្ត

- □ ចូលចិត្តហុចវត្ថុទៅឱ្យអ្នកដទៃនៅពេលលេង
- □ អាចមានអារម្មណ៍មួម៉ៅខ្លាំង
- □ អាចភ័យខ្លាចមនុស្សចម្លែក
- □ បង្ហាញការស្រឡាញ់ចូលចិត្តដល់មនុស្សដែលធ្លាប់ស្គាល់
- □ លេងធ្វើពុត ដូចជាបញ្ចុកចំណីកូនក្រមុំក្មេងលេង
- □ អាចតោងកាន់អ្នកមើលថែក្នុងស្ថានភាពថ្មី
- □ ចេះចង្អុលប្រាប់អ្នកផ្សេងទៀតអំពីអ្វីដែលគួរឱ្យចាប់អារម្មណ៍
- □ រុករកដោយខ្លួនឯង ប៉ុន្តែមានឪពុកម្តាយនៅក្បែរ

### ភាសា / ការទំនាក់ទំនង

- □ ចេះនិយាយពាក្យមួយម៉ាត់ជាច្រើន
- □ និយាយ ហើយគ្រវីក្បាលថា "ទេ"
- □ ចង្អុលប្រាប់នរណាម្នាក់ពីអ្វីដែលវាចង់បាន

### ការយល់ដឹង (ការរៀន ការដោះស្រាយបញ្ហា)

- □ ដឹងពីវត្ថុសាមញ្ញគឺប្រើសម្រាប់គោលបំណងអ្វី ឧទាហរណ៍ ទូរស័ព្ទ ច្រាស ស្លាបព្រា
- □ ចង្អុលដើម្បីទទួលបានការយកចិត្តទុកដាក់ពីអ្នកដទៃ
- □ បង្ហាញពីចំណាប់អារម្មណ៍ចំពោះកូនក្រមុំក្មេងលេង ឬសត្វញាត់សំឡី ឬក្រណាត់សម្រាប់ក្មេងលេង ដោយលេងធ្វើពុតដើម្បីបញ្ចុកចំណី
- □ ចង្អុលទៅផ្នែករាងកាយមួយ
- □ ចេះគូសវាសដោយខ្លួនឯងផ្ទាល់
- □ ចេះធ្វើតាមការបញ្ជាប្រាប់១ជំហាន ដោយពុំបាច់បញ្ចេញកាយវិការ ឧទាហរណ៍ អង្គុយចុះ នៅពេលអ្នកនិយាយថា "អង្គុយចុះ"

# កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ

## ការរីកចម្រើនផ្នែកចលនា / រាងកាយ

- ☐ ចេះដើរដោយខ្លួនឯង
- ☐ អាចដើរឡើងជណ្តើរ ហើយរត់
- ☐ ទាញប្រដាប់ក្មេងលេង ខណៈកំពុងដើរ
- ☐ អាចជួយដោះសំលៀកបំពាក់ដោយខ្លួនឯងផ្ទាល់
- ☐ ចេះផឹកចេញពីពែង
- ☐ ចេះញ៉ាំជាមួយស្លាបព្រា

## ចាត់វិធានការឱ្យបានមុនពេល ដោយនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់កូនអ្នក ឬគិលានុបដ្ឋាក ផ្នែកសុខភាពកុមារ និងគ្រួសារ ប្រសិនបើកូនរបស់អ្នក:

- ☐ ពុំចង្អុលប្រាប់ពីអ្វីដល់អ្នកផ្សេងទៀត
- ☐ ពុំអាចដើរបាន
- ☐ ពុំដឹងពីវត្ថុដែលធ្លាប់ស្គាល់គឺសម្រាប់អ្វី
- ☐ ពុំចម្លងធ្វើតាមអ្នកដទៃទៀត
- ☐ ពុំរៀនចេះពាក្យថ្មីៗ
- ☐ ពុំចេះយ៉ាងហោចណាស់៦ពាក្យ
- ☐ ពុំកត់សម្គាល់ឃើញ ឬពុំយល់ទាស់នៅពេលអ្នកថែទាំចាកចេញ ឬត្រឡប់មកវិញ
- ☐ បាត់បង់ជំនាញដែលធ្លាប់មានពីមុនៗ។

---

សម្រាប់គំនិតបន្ថែមទៀត អំពីការចំណាយពេលវេលាជាមួយខ្ញុំ សូមចូលទៅកាន់: *Love, talk, sing, read, play (ក្តីស្រឡាញ់ និយាយ ច្រៀង អាន លេង)* **www.lovetalksingreadplay.com.au**។ ធនធានដែលបានផ្តល់ដោយការផ្តល់ធនធានសម្រាប់ឪពុកម្តាយ។

ភាសាសម្របសម្រួលសម្រាប់ភាសាអង់គ្លេសអូស្ត្រាលីដោយរដ្ឋ NSW Ministry of Health. Original content provided by the U.S. Centers for Disease Control and Prevention's *Learn the Signs. Act Early.* Program (**www.cdc.gov/ActEarly**; June 2017) ខែមិថុនា ឆ្នាំ២០១៧)។

---

# សំណួរបន្ថែមទៀតសម្រាប់ឪពុកម្តាយ / អ្នកថែទាំ

**សូមឆ្លើយសំណួរទាំងនេះ មុនពេលអ្នកទៅជួបគិលានុបដ្ឋាក ឬវេជ្ជបណ្ឌិតរបស់អ្នក សម្រាប់ការពិនិត្យសុខភាពអាយុ១៨ខែ។**

| | |
|---|---|
| ខ្ញុំបានបំពេញសំណួរអំពីកត្តាហានិភ័យផ្នែកសុខភាពនៅទំព័រ 21 រួចហើយ | ទេ \| បាទ/ចាស់ |
